# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីសីល៥របស់ព្រះពុទ្ធសាសនាដែលព្រះពុទ្ធបាន
## ប្រកាសឲ្យពុទ្ធបរិស័ទជាគ្រហស្ថកាន់ឲ្យបានគ្រប់គ្នា

**web site ៖ hoksavann.org**

ថ្ងៃទី២៦ វិច្ឆិកា ២០០៥

សីល៥ជាគោលសីលធម៌របស់មនុស្ស ដែលព្រះពុទ្ធបានបង្រៀនឲ្យមនុស្សទូទៅ ជាពិសេសឲ្យពុទ្ធបរិស័ទរបស់ព្រះអង្គគោរពកាន់គ្រប់គ្នា អស់កាលជានិច្ច ហើយសីល៥នេះ ពុទ្ធបរិស័ទជាគ្រហស្ថតែងតែទទួលសមាទានពីព្រះសង្ឃ បន្ទាប់ពីនមស្សការរួចរាល់ពេលធ្វើបុណ្យទានក្នុងព្រះពុទ្ធសាសនា ។ សីលបានដល់ចេតនាល្អ វៀរចាកសេចក្តីអាក្រក់ តាមផ្លូវកាយ និងវាចា ។ សីលមានន័យច្រើនយ៉ាង គឺសីលនំ សីលមានន័យថាប្រក្រតី បានដល់ប្រក្រតីខាងល្អ គឺប្រព្រឹត្តល្អជាប្រក្រតី, សិរដ្ឋោសីល មានន័យថាជាកំពូល គឺបើមានសីលហើយ កុសលដទៃទៀតរមែងកើតមាន, សីសដ្ឋោ សីលមានន័យថាជាប្រធាន គឺបើមានសីលជាប្រធានដឹកនាំហើយ កុសលដទៃទៀតរមែងកើតមាន, សីតលដ្ឋោ សីលមានន័យថាត្រជាក់ គឺបុគ្គលមានសីល រមែងមានចិត្តត្រជាក់ មិនក្តៅក្រហាយស្តាយក្រោយ នូវអំពើដែលធ្វើខុស ។

សីល៥មានសិក្ខាបទ៥គឺ ៖

១- បាណាតិបាតា វេរមណី ហាមមិនឲ្យសម្លាប់សត្វ គឺហាមមិនឲ្យសម្លាប់ជីវិតមនុស្សសត្វទូទៅ ដែលមានជីវិតសញ្ញាស្រឡាញ់ជីវិត ចង់រស់មិនចង់ស្លាប់ មានការភ័យតក់ស្លុតចំពោះការគំរាមកំហែងគ្រប់យ៉ាង ។ ការដែលព្រះពុទ្ធហាមមិនឲ្យសម្លាប់ គឺជាការគោរពជីវិតអ្នកដទៃ ការសម្លាប់ឈ្មោះថារំលោភលើជីវិតអ្នកដទៃ ព្រោះមនុស្សសត្វគ្រប់រូបមានសិទ្ធិរស់នៅដូចគ្នា ។ ផ្លូវអាណាចក្រ គេបង្កើតច្បាប់បង្កើតប៉ូលិស ដើម្បីការពារសន្តិសុខជូនប្រជាពលរដ្ឋដោយមានការសម្លាប់គ្នា ។ ដូច្នេះបើមនុស្សទាំងអស់កាន់សិក្ខាបទទី១នេះរបស់ព្រះពុទ្ធ គឺមិនសម្លាប់គ្នា ពិតជាជួយសំរួលដល់ផ្លូវអាណាចក្រ មិនចំណាយប្រាក់កាសបង្កើតប៉ូលិសដើម្បីបង្ក្រាបអ្នកសម្លា

ប់ឡើយ ។

២- អទិន្នាទានា វេរមណី ហាមមិនឲ្យកាន់យកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ដោយចេតនាលួច ។ ការហាមមិនឲ្យលួចក៏ជាការគោរពកម្មសិទ្ធិ ទ្រព្យសម្បត្តិអ្នកដទៃ ដោយត្រូវគិតថា យើងស្រឡាញ់ទ្រព្យសម្បត្តិរបស់ខ្លួន មិនចង់ឲ្យបាត់បង់យ៉ាងណា អ្នកដទៃក៏មានចិត្តបែបនោះដូចគ្នា ។ ផ្លូវអាណាចក្រ រដ្ឋបានចំណាយថវិកាជាច្រើនក្នុងការបង្ក្រាប ចោរលួច ចោរប្លន់ ចោរឆក់ ការកេងប្រវ័ញ្ចគ្នាគ្រប់បែបយ៉ាង ។ បើចោរជាប្រជាជនធម្មតាស្រណុកបង្ក្រាប ប៉ុន្តែបើចោររដ្ឋការស៊ីសំណូកពុករលួយ ដូចចោរអ្នករដ្ឋការខ្មែរសព្វថ្ងៃ លួចកាប់ដើមឈើជាសម្បត្តិធម្មជាតិរបស់រដ្ឋ ដើរប្លន់យកដីប្រជាជនជាដើម ជាមហាចោរពិបាកបង្ក្រាបណាស់ ។ ដូច្នេះ បើគេកាន់សិក្ខាបទទី២ កុំលួចកុំប្លន់ បញ្ហាដូចពោលមកនេះពុំកើតមានឡើយ ជាការជួយសំរួលដល់ផ្លូវអាណាចក្រឲ្យមានការភ័យខ្លាចពីការបាត់បង់ទ្រព្យសម្បត្តិនិងរបស់ជាតិ ទៅណាមកណាមិនចាំបាច់ចាក់សោរផ្ទះទេ ព្រោះគ្មានចោរលួច ។

៣- កាមេសុ មិច្ឆាចារា វេរមណី វៀរចាកការលួចប្រពន្ធកូនប្តីអ្នកដទៃ គឺជាការគោរពកម្មសិទ្ធិនៃកូនប្រពន្ធនិងប្តីរបស់អ្នកដទៃ ។ មួយភាគធំនៃជម្លោះរហូតដល់កើតអំពើហឹង្សា គឺកើតមកពីរំលោភផ្លូវភេទនេះឯង បើគេគោរពតាមសិក្ខាបទទី៣នេះ បញ្ហាព្យាបាទគ្នាដោយអំពើលួចសម្លាប់ ការជះទឹកអាស៊ីដដាក់គ្នា និងរោគអេដស៍ពុំកើតមានឡើយ ។

៤- មុសាវេទា វេរមណី វៀតចាកការពោលពាក្យកុហក ពាក្យពុំពិត ព្រោះបើគេយកទៅធ្វើតាម នាំឲ្យខូចប្រយោជន៍គេ ។ ការពោលពាក្យពុំពិត នាំឲ្យមនុស្សលែងទុកចិត្តគ្នា នាំឲ្យបែកសាមគ្គីគ្នា ។ ចំពោះបញ្ហាជាតិ បើអ្នកដឹកនាំស្មោះត្រង់និងប្រជាពលរដ្ឋពោលពាក្យពិត ពុំភូតកុហកប្រជាពលរដ្ឋ ដែលមានលក្ខណៈធ្វើប្រជាភិថុតិ នោះសាមគ្គីជាតិនិងឯកភាពជាតិរមែងកើតមាន ។

៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វៀរចាកការផឹក ការជក់គ្រឿងស្រវឹង គ្រឿងញៀនគ្រប់ប្រភេទ ។ បើប្រព្រឹត្តឲ្យកន្លងសិក្ខាបទទី៥នេះ មានទោស៦យ៉ាង គឺ ចំណាយថវិកាគ្រួសារលើសការចំណាយធម្មតា, នាំបង្កើតជម្លោះ, នាំឲ្យកើតរោគ, ខូចកេរ្តិ៍ឈ្មោះ, បង្ហាញកេរ្តិ៍ខ្មាស់, ធ្វើឲ្យខ្សោយប្រាជ្ញាស្មារតី ។

ដូចបានពោលមកហើយ គ្រាន់តែលើកយកសីល៥មកបង្ហាញប៉ុណ្ណោះបញ្ជាក់ថា ព្រះពុទ្ធសាសនាមានធម៌សំរាប់អប់រំមនុស្សក្នុងសង្គម ឲ្យមានសុខសន្តិភាពរស់នៅជាមួយគ្នា ប្រកបដោយសុខដមរមនា ។៚

❑ ❑

❑